សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា
The Cambodian Human Rights and Development Association (ADHOC)

# ជ្រើសរើសមេធាវី

## ប្រវត្តិសមាគមអាដហុក:

សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ហៅកាត់ថា អាដហុក គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ អព្យាក្រឹត មិនប្រកាន់និន្នាការគណៈបក្សនយោបាយ និងមិនស្វែងរកប្រាក់ចំណេញ បានបង្កើតឡើងនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩១ និងបានចុះបញ្ជីនៅក្រសួងមហាផ្ទៃនៅថ្ងៃទី២៨ ខែមិនា ឆ្នាំ ២០០០ ព្រមទាំងមានទីស្នាក់ការកណ្តាលនៅ រាជធានីភ្នំពេញ និងមានការិយាល័យនៅតាមខេត្តរាជធានី ចំនួន ១៧ ។

សមាគមអាដហុក ធ្វើការដើម្បីស្តាបនាឲ្យមានឡើងវិញនូវសិទ្ធិ សេរីភាពជាមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា តាមរយៈការអប់រំ បង្កើនចំណេះដឹងផ្នែកអំពីសិទ្ធិមនុស្ស និងច្បាប់ ដើម្បីប្រជាពលរដ្ឋ យល់ដឹងអំពីសិទ្ធិមនុស្សប្រជាធិបតេយ្យ និងចេះការពារសិទ្ធិដោយខ្លួនឯង។ គោលបំណងរបស់សមាគមអាដហុក គឺការពារជនរងគ្រោះពីការរំលោភបំពាននៅក្នុងការស្វែងរកយុត្តិធម៌ ពង្រឹងសមត្ថភាពរបស់ប្រជាពលរដ្ឋនៅក្នុងការទាមទារសិទ្ធិរបស់ពួកគេ និងលើកទឹកចិត្តប្រជាពលរដ្ឋឱ្យបញ្ចុះបញ្ចូល និងតស៊ូមតិ ដើម្បីកែលម្អច្បាប់ ស្ថាប័ននានា និងការអនុវត្តច្បាប់។

**១. លក្ខណៈនៃកិច្ចសន្យា:** រយៈពេលកិច្ចសន្យាការងារមិនកំណត់បន្ទាប់ពីបានបញ្ចប់ដោយជោគជ័យនូវការងារសាកល្បងរយៈពេល ៣ខែ។

## ២. ភារកិច្ច និងការទទួលខុសត្រូវជាក់លាក់៖

- ការពារក្តី ករណីរំលោភសិទ្ធិមនុស្ស ដីធ្លី ធនធានធម្មជាតិ ស្ត្រី និងកុមារ ជាពិសេសសកម្មជន
- ធ្វើរបាយការណ៍លទ្ធផលមេធាវីសំរាប់ ៦ខែ និង ប្រចាំឆ្នាំ
- ផ្តល់បទសម្ភាសន៍ទៅអ្នកសាព័ត៌មានលើករណីខ្លួនការពារ
- ផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ដល់បុគ្គលិកអាដហុក និង ជនរងគ្រោះ(ករណីអ្នកអង្កេតជាប់រវល់) ។
- ចូលជាវាគ្មិនក្នុងកម្មវិធីផ្សេងៗដូចជា: សិក្ខាសាលា វិទ្យុ ...
- ជួយរៀបចំ ឬ កែរសម្រួលឯកសារផ្សេងៗដូចជា: សេចក្តីថ្លែងការណ៍ លិខិតអន្តរាគមន៍ ឯកសារមេរៀន... ដែលទាក់ទងនឹងវិស័យច្បាប់ ។

- រៀបចំតារាងបំពេញការងារ (Time-sheet) ប្រចាំខែ
- ប្រធានផ្នែក ផ្តល់តួនាទី/ ភារកិច្ចលើសពីការចែងខាងលើ ប្រសិនបើមានករណីចាំបាច់

## ៣. សមត្ថភាព និងគុណវុឌ្ឍិចាំបាច់៖

- មានអាយុចាប់ពី ២៥ ឆ្នាំឡើងទៅ
- មានកំរិតវប្បធម៌ថ្នាក់ បរិញ្ញាបត្រផ្នែកច្បាប់ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- មានបទពិសោធន៍ធ្វើការងារជាមួយអង្គការសិទ្ធិមនុស្សជាតិ អន្តរជាតិ ចាប់ពីពីរឆ្នាំឡើងទៅ
- មានភាពស្មោះត្រង់ និងគួរឱ្យទុកចិត្ត និងក្រមសីលធម៌ការងាររឹងមាំ។
- មានសេចក្តីក្លាហាន និងចំណេះដឹងផ្នែកសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ
- ចេះភាសាខ្មែរស្ទាត់ជំនាញក្នុងការនិយាយ និងសរសេរ
- មានសមត្ថភាពអាចនិយាយ និងសរសេរជាភាសាអង់គ្លេស
- មានជំនាញទំនាក់ទំនងផ្ទាល់មាត់ និងសរសេរបានប្រកបដោយប្រសិទ្ធភាព
- ជំនាញសរសេររបាយការណ៍យ៉ាងល្អ និង
- មានជំនាញខាងកុំព្យូទ័រ Microsoft Word, Excel ។

## ៤. តម្រូវការចាំបាច់

- មានបទពិសោធន៍ធ្វើការជាមួយអាជ្ញាធរថ្នាក់ជាតិ និងក្រោមជាតិទាក់ទងនឹងដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ យល់ដឹងអំពីសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ។
- ការសិក្សាក្រោយឧត្តមសិក្សាត្រូវបានបំពេញ។
- បានបំពេញបទពិសោធន៍ការងារក្រោយឧត្តមសិក្សាជាច្រើនឆ្នាំ។